# បណ្តាំរៀមច្បង

(បទពាក្យ៧)

មើលឃើញសង្គមដ៏ទំនើប រំភើបចិន្តាឥតគណនា
គយគន់គិតគួរគ្រប់វេលា បែរជាអារម្មណ៍ព្រួចព្រួយភ័យ។
ចាប់ចិត្តចង់ចែងតែងកំណាព្យ ផ្ញើកាព្យផ្តែផ្តាំប្អូនប្រុសស្រី
អោយបានស្តែងស្តាប់ច្បាប់ប្រពៃ វិថីជីវិតផុតឧបសគ្គ។
ប្អូនអើយចូរស្តាប់ចាប់អោយបាន គ្រប់ប្រាណនឹងបានយល់ប្រត្យក្ស
ជីវិតយុវវ័យសែនគ្រោះថ្នាក់ បើអាក់ខកខានមិនបានគិត។
មើលចុះអ្វីៗសុទ្ធទំនើប ស្ទុះផើបប្រណាំងខ្សែជីវិត
ហ៊ីហាហិចហក់ហួសក្រមក្រឹត្យ ជុំជិតទៅដោយគ្រឿងអបាយ។
ក្នុងបឋមវ័យគួរប្រញាប់ កំចាត់ហ្មងសៅទៅអោយឆ្ងាយ
កុំភ្លឹកភ្លើតភ្លើនព្រហើនកាយ លង់ល្បាយពិសពុលនៃសង្គម។
ចូរស្តាប់ឱវាទអ្នកមានគុណ ជាទុនផ្តល់សុខលើទ្រទំ
មាតាបិតាលោកជាធំ ប្អូនកុំប្រមាថខាតក្តីគាប់។
នាមជាកុលបុត្រទាំងប្រុសស្រី គប្បីគោរពឱនគំនាប់
ម៉ែឪប្រដៅហៅផ្តល់ភ័ព្វ គួររាប់គួររកយកជាផ្លូវ។
មាតាបិតាខំថ្នមថ្នាក់ ឥតអាក់គ្រប់ខែឆ្នាំរដូវ
ចង់ឃើញកូនស្ងួនផុតអាស្រូវ រស់នៅថ្លៃថ្នូរមានសីលធម៌ ។
ទោះលោកតោកយ៉ាកលំបាកកាយ មិនស្តាយកំលាំងធ្វើរបរ
ត្រដាបត្រដួសខំត្រដរ ស្វែងរកមាសប្រាក់ដើម្បីកូន ។
ដឹកនាំពាំជូនទៅសាលា សិក្សាវិជ្ជាទុកជាក្សន
ជួយឃឹតសណ្តោងយោងសណ្តូន នាំកូនចូលផែនភពពណ្ណរាយ។
ប្អូនគិតមើលចុះណាប្អូនណា ជីវ៉ានឹងបានយល់ធ្លុះធ្លាយ
គុណគាប់បើរាប់នោះមិនងាយ ដឹកស្តាយមិនអស់សងមិនរួច។
បើប្អូនអាណិតឪពុកម្តាយ ឆោមឆាយកុំរឹងកុំលាក់លួច
កុំចោលឱវាទដែលលោកផ្តួច សម្រួចថ្វាថ្លែងចែងពន្យល់។
តាំងចិត្តសូត្ររៀនកុំងាករេ រាប់គេអ្នកល្អចិត្តនិមល
កុំយកចិត្តពាលជាមណ្ឌល ត្រូវយល់តម្លៃសេពគប់មិត្ត។

សង្គមច្របល់ចំរុះពណ៌ ខៀវ ស ក្រហម ខ្មៅ ងងឹត
ចូរបើកនេត្រាគន់ពិនិត្យ ចរិតនិស្ស័យដែលបវរ។
នរណាចូលចិត្តផ្លូវអបាយ សហាយ ស្រីស្រា រាត្រីចរ
ល្បែងល្បាំរាំរែកត្រេកអ៊ូអរ រីកវរប្រឈ្លោះមោះបញ្ហា។
មិនស្គាល់ចាស់ទុំឬខ្ពស់ទាប សភាពមិនស្គាល់គុណសាសនា
ពុំមានសីលធម៌ជាប់កាយា ជីវ៉ាចូរចៀសចេញអោយឆ្ងាយ។
រាប់គេអ្នកល្អឫកប្រពៃ និស្ស័យថ្លៃថ្នូរជាប់ចិត្តកាយ
យកការសិក្សាជាតម្រាយ សប្បាយនឹងរៀនសូត្រទន្ទេញ។
ចេះស្គាល់បាបបុណ្យគុណទោសា វិចារណ៍មុនធ្វើចៀសទោម្នេញ
ផ្លូវណាល្អគាប់មិនបែរចេញ បំពេញបំណងអ្នកមានគុណ។
ជននេះប្អូនត្រូវតោងអោយជាប់ ជាភ័ព្វកុសលផុតស៊ិយស៊ុន
បានសេពគប់ហើយផុតទារុណ សគុណចាកឆ្ងាយពីទោសភ័យ។
សេពគប់ជនពាលជួបតែទុក្ខ ថ្ងៃមុខនឹងសោកបរាជ័យ
សេពគប់អ្នកល្អសុទ្ធប្រពៃ និស្ស័យបានជួបតែក្តីសុខ។
ប្អូនទាំងប្រុសស្រីវ័យបឋម មាសម៉ុមប្រុសពៅកុំសំកុក
វិចារណ៍ពាក្យពេចន៍ហើយចាំទុក រកសុខរកសាន្តប្រាណភិរម្យ។
ព្យាយាមទាមទារអនាគត អោយផុតក្តីទុក្ខក្តៅអួលងំ
សីលធម៌រស់នៅក្នុងសង្គម បន្ទំអបស្ចុបការសិក្សា។
ទំនៀមធ្វើពាលវាមិនគាប់ នឹងជាប់តែទុក្ខត្រូវផ្កាសា
ទំលាប់ធ្វើល្អណាប្អូនណ៎ា ផ្លែផ្កាគឺសុខលុះអវសាន។
ជីវិតនឹងស្គាល់តែខ្ពង់ខ្ពស់ កេរ្តិ៍ឈ្មោះក្រអូបសព្វទីឋាន
កិត្តិយសបវរល្អថ្កើងថ្កាន សុខសាន្តប្រាណចិត្តត្បិតសាងល្អ។

*(១២ ឧសភា ២០០០)*

*ភិក្ខុវណ្ណគុត្តោ ស្វាត សាលឿម*